# ឯកសារស្តីពីគោលគំនិត
# និងយុទ្ធសាស្ត្រនៃការពិគ្រោះយោបល់

---

**កម្មវិធីសហភាពអឺរ៉ុបដើម្បីលើកកម្ពស់ការបំពេញការងារ គណនេយ្យភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ (EU-SPACE)**

**អនុវត្តដោយៈ GIZ**

ខែមិថុនា ឆ្នាំ២០១២

# មាតិកា


សេចក្តីផ្តើម ..... ២

គោលគំនិតនៃការពិគ្រោះយោបល់ ..... ៣

តើអ្វីគឺជាការពិគ្រោះយោបល់? ..... ៣

គោលបំណងនៃការពិគ្រោះយោបល់ ..... ៤

ឥរិយាបថជាមូលដ្ឋានរបស់អ្នកពិគ្រោះយោបល់ ..... ៤

ការប្រឹក្សាយោបល់បច្ចេកទេស ការពិគ្រោះយោបល់ និងការបង្ហាត់បង្ហាញ ..... ៦

ការប្រឹក្សាយោបល់បច្ចេកទេស ..... ៦

ការពិគ្រោះយោបល់ ..... ៦

ការបង្ហាត់បង្ហាញ ..... ៦

ចរិតលក្ខណៈនៃការផ្តល់ប្រឹក្សាបច្ចេកទេស និងការពិគ្រោះយោបល់ ..... ៨

ការបញ្ជាក់តួនាទីសម្រាប់អ្នកពិគ្រោះយោបល់ ..... ៩

ទាក់ទងទៅនឹងពាក្យ "តួនាទី" ..... ៩

សារៈសំខាន់នៃការយល់អំពីតួនាទីសម្រាប់ការពិគ្រោះយោបល់ និងការងារផ្តល់ប្រឹក្សា ..... ១០

តួនាទីនៃការពិគ្រោះយោបល់នៅក្នុងការងារវិមជ្ឈការ ..... ១១

តួនាទីផ្សេងៗនៃការផ្តល់ប្រឹក្សា ..... ១៣

ជំនាញចាំបាច់សម្រាប់ការពិគ្រោះយោបល់ ..... ១៣

ដំណាក់កាលនៃការពិគ្រោះយោបល់ ..... ១៦

ដ្យាក្រាមនៃដំណើរការពិគ្រោះយោបល់ ..... ១៨

ការបង្កើតកិច្ចតែងការអំពីការពិគ្រោះយោបល់ ..... ១៩

ទម្រង់សង្កេតការពិគ្រោះយោបល់ ..... ២០

គន្លឹះសំខាន់ៗសម្រាប់រៀបចំកិច្ចតែងការពិគ្រោះយោបល់ ..... ២២

គំរូកិច្ចតែងការសម្រាប់ការពិគ្រោះយោបល់ ..... ២២

## សេចក្តីផ្តើម

ការពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ គឺជាសកម្មភាពស្នូលមួយរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ដូចដែលមានចែងនៅក្នុងឯកសារគោលនយោបាយដែលពាក់ព័ន្ធដូចជា កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) និងផែនការអនុវត្តរយៈពេលបីឆ្នាំ (ផ.អ៣)។ កម្មវិធី SPACE ដែលផ្តល់មូលនិធិដោយសហភាពអឺរ៉ុបគាំទ្រដល់លេខាធិការដ្ឋាន គ.ជ.អ.ប នៅក្នុងការអនុវត្ត NP-SNDD និង ផ.អ៣ ដោយផ្តោតលើដំណើរការស្នូលពីរ ដែលរួមមានការបញ្ជ្រាបគណនេយ្យភាពតាមបែបប្រជាធិបតេយ្យនៅក្នុងដំណើរការរៀបចំគោលនយោបាយ នៃកំណែទម្រង់អភិបាលកិច្ចតាមបែបវិមជ្ឈការ និងការពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិនៅក្នុងខេត្តគំរូចំនួនពីរ គឺ កំពង់ឆ្នាំង និងបាត់ដំបង តាមរយៈការរៀបចំឯកសារបច្ចេកទេស និងការអនុវត្តសាកល្បងនូវនីតិវិធី តាមរយៈការប្រឹក្សាយោបល់ ការបណ្តុះបណ្តាលសិក្ខាសាលា និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ។

ដោយមានការគាំទ្រពីកម្មវិធី EU-SPACE ឯកសារស្តីពីគោលគំនិតនៃការពិគ្រោះយោបល់ត្រូវបានរៀបចំឡើង និងត្រូវបានប្រើប្រាស់ជាវិធីសាស្ត្រអភិវឌ្ឍសមត្ថភាពស្នូលដើម្បីពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សានៅ ក្នុងខេត្តគោលដៅ។ គោលគំនិតនៃការពិគ្រោះយោបល់នៅក្នុងក្របខ័ណ្ឌនៃកម្មវិធី EU-SPACE គឺដើម្បីកែលម្អការអនុវត្តការងារ និងគណនេយ្យភាពរបស់ក្រុមប្រឹក្សាគោលដៅ ជាពិសេសនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត និងការត្រួតពិនិត្យការអនុវត្តសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា ដោយរដ្ឋបាលដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

ឯកសារនេះរៀបរាប់អំពីគោលគំនិតនៃការពិគ្រោះយោបល់ ភាពខុសគ្នារវាងការប្រឹក្សាយោបល់បច្ចេកទេស (Expert Advice) និងការពិគ្រោះយោបល់ (Coaching) ឥរិយាបថជាមូលដ្ឋានរបស់អ្នកពិគ្រោះយោបល់ គោលបំណងនៃការពិគ្រោះយោបល់ ជំនាញចាំបាច់សម្រាប់ការពិគ្រោះយោបល់ និងដំណើរការនៃការ ពិគ្រោះយោបល់ ដូចដែលបានអនុវត្តនៅក្នុងសកម្មភាពគាំទ្ររបស់កម្មវិធី EU-SPACE។ ឯកសារនេះ ក៏បានបង្ហាញផងដែរអំពីជំនាញក្នុងការសួរសំណួរ ដោយប្រើប្រាស់ប្រភេទសំណួរផ្សេងៗ ដើម្បីជួយក្រុមគោលដៅ ពោលគឺសមាជិកក្រុមប្រឹក្សា ដើម្បីបង្កើតដំណោះស្រាយ ក្នុងការធ្វើឱ្យប្រសើរឡើងនូវការបំពេញការងារ និងការអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់ពួកគេ។ វិធីសាស្ត្ររៀបចំកិច្ចតែងការសម្រាប់ការពិគ្រោះយោបល់ និងគំរូនៃកិច្ចតែងការសម្រាប់ការពិគ្រោះយោបល់ ដែលបង្ហាញនៅក្នុងឯកសារនេះផ្តល់នូវគំនិតបន្ថែមទៀតសម្រាប់អ្នកអនុវត្តផ្ទាល់ក្នុងការអភិវឌ្ឍសមត្ថភាព។

ឯកសារនេះអាចត្រូវបានប្រើប្រាស់ជាឯកសារគោលគំនិតស្តីអំពីការពិគ្រោះយោបល់ ដើម្បីជួយដល់អ្នក សម្របសម្រួលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាដែលជាប់ឆ្នោតបំពេញការងារ និងភារកិច្ចរបស់ខ្លួនឲ្យកាន់តែប្រសើរឡើង។ ឯកសារនេះត្រូវបានគេរំពឹងថានឹងអាចជួយដល់អ្នកសម្របសម្រួល ដើម្បីអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិនៅទូទាំងប្រទេស ក្នុងនាម ជាអ្នកនយោបាយនៅមូលដ្ឋានដែលត្រូវមានគណនេយ្យភាព និងភាពឆ្លើយតបចំពោះប្រជាពលរដ្ឋ។

## ១. គោលគំនិតនៃការពិគ្រោះយោបល់

### ក. តើអ្វីគឺជាការពិគ្រោះយោបល់?

ការពិគ្រោះយោបល់ គឺជាជំនួយបច្ចេកទេសដោយផ្អែកលើដំណើរការ ដើម្បីគាំទ្រដល់ក្រុមប្រឹក្សាគោលដៅក្នុងខេត្តគំរូ ដើម្បីពង្រឹងការបំពេញការងារ និងការធ្វើសេចក្តីសម្រេចចិត្ត ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្នុងបរិបទនេះ និយមន័យខាងក្រោមនឹងត្រូវបានយកមកប្រើប្រាស់។

*ការពិគ្រោះយោបល់ (Coaching) គឺជាការដំណើរការជជែកពិភាក្សាក្នុងការជួយដល់ក្រុមគោលដៅ ដើម្បីធ្វើឱ្យប្រសើរឡើងទាំងការអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងការបំពេញការងារ។ វាគឺជាជំនួយបច្ចេកទេសដែលផ្តោតទៅលើតម្រូវការ (demand-oriented assistance) ដើម្បីជួយដល់ក្រុមគោលដៅ ក្នុងការវិភាគបញ្ហាជាក់លាក់ និងបង្កើតដំណោះស្រាយសមស្របលើបញ្ហាទាំងនោះ។*

ជាទូទៅ ការពិគ្រោះយោបល់ គឺជាការជជែកពិភាក្សាមួយដែលផ្តោតលើដំណើរការ ដែលរួមមានការពិគ្រោះយោបល់មួយទល់នឹងមួយ។ វាផ្តោតសំខាន់ទៅលើការផ្លាស់ប្តូរឥរិយាបថរបស់ក្រុមគោលដៅ ក្នុងការបំពេញការងារ និងជំនាញវិជ្ជាជីវៈ។ ទោះបីជាយ៉ាងណាក្តី សម្រាប់ការអនុវត្តជាក់ស្តែង ការពិគ្រោះយោបល់មួយទល់នឹងមួយមិនអាចធ្វើទៅបានទេ។ នៅក្នុងក្របខ័ណ្ឌនៃសកម្មភាពដែលគាំទ្រដោយ EU-SPACE និងបរិបទជាក់ស្តែងរបស់ក្រុម ប្រឹក្សា ការពិគ្រោះយោបល់ត្រូវបានអនុវត្តសម្រាប់ក្រុមគោលដៅជាបុគ្គល (ប្រធានក្រុមប្រឹក្សាអភិបាល នាយករដ្ឋបាល...។ល។) ឬ ជាក្រុម (សមាជិកក្រុមប្រឹក្សាទាំងមូល គណៈអភិបាល និងបុគ្គលិករដ្ឋបាលសំខាន់ៗ...។ល។) នៃខេត្តគំរូ។ សមាជិកក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលសំខាន់ៗនឹងចូលរួមក្នុងសិក្ខាសាលាតម្រង់ទិស និងការបណ្តុះបណ្តាលនានាអំពីប្រធានបទដែលពាក់ព័ន្ធ (លិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធ ឯកសារបច្ចេកទេស...។ល។) មុននឹងអនុវត្តគោលគំនិតនៃការពិគ្រោះយោបល់។ បន្ទាប់មក ប្រធានបទនៃការពិគ្រោះយោបល់ត្រូវបានកំណត់ដោយផ្អែកលើតម្រូវការរបស់ក្រុមប្រឹក្សានៅក្នុងការអនុវត្តលិខិតបទដ្ឋានគតិយុត្តិ ឬគំរូនៃឯកសារបច្ចេកទេស[1]។ ដូច្នេះ ការពិគ្រោះយោបល់ជាក្រុម (មានលក្ខណៈជាការសម្របសម្រួលច្រើនជាង) ត្រូវបានគេរំពឹងថា នឹងត្រូវបានអនុវត្តមិនត្រឹមតែដោយទីប្រឹក្សា

---

[1] ឯកសារបច្ចេកទេស គឺជាឯកសារណែនាំបច្ចេកទេសជាជម្រើស ដើម្បីគាំទ្រដល់ក្រុមប្រឹក្សានៅក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន ដែលជាអ្នកនយោបាយជាប់ឆ្នោតនៅមូលដ្ឋាន។ មានឯកសារបច្ចេកទេសមួយចំនួន ( ឧទាហរណ៍ ឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំក្រុមប្រឹក្សា ឯកសារបច្ចេកទេសស្តីពីវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ ឯកសារបច្ចេកទេសស្តីពីទំនាក់ទំនងអន្តររដ្ឋបាល...។ល។ ) ត្រូវបានរៀបចំឡើងដើម្បីគាំទ្រដល់ក្រុមប្រឹក្សានៅក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនដើម្បីឆ្លើយតបនឹងតម្រូវការនៅមូលដ្ឋាន។

អភិបាលកិច្ចមូលដ្ឋាននៅថ្នាក់ខេត្តរបស់កម្មវិធី EU-SPACE ក្នុងខេត្តគំរូប៉ុណ្ណោះទេ ប៉ុន្តែអាចត្រូវបានប្រើប្រាស់ដោយអ្នកសម្របសម្រួលរបស់ គ.ជ.អ.ប នៅទូទាំងប្រទេសផងដែរ។

### ខ. គោលបំណងនៃការពិគ្រោះយោបល់

គោលបំណងចម្បងនៃការពិគ្រោះយោបល់គឺដើម្បីគាំទ្រដល់ក្រុមគោលដៅ បង្កើតជាជម្រើសនានាសម្រាប់ការបំពេញការងារ និងអភិវឌ្ឍជំនាញវិជ្ជាជីវៈ។

នៅក្នុងក្របខ័ណ្ឌនៃកម្មវិធី EU-SPACE, គោលបំណងចម្បងនៃការពិគ្រោះយោបល់ គឺដើម្បីជួយគាំទ្រដល់សមាជិកក្រុមប្រឹក្សានៅក្នុងខេត្តគោលដៅអំពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដោយសាកល្បងនីតិវិធី និងទម្រង់គំរូនានាដើម្បីដោះស្រាយបញ្ហានៅថ្នាក់មូលដ្ឋាន។ តាមរយៈដំណើរការពិគ្រោះយោបល់ សមាជិកក្រុមប្រឹក្សានឹងទទួលបាននូវទំនុកចិត្តលើខ្លួនឯងនៅក្នុង ការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួនប្រកបដោយលក្ខណៈឆ្លើយតប និងមានគណនេយ្យភាព។

## ២. ឥរិយាបថជាមូលដ្ឋានរបស់អ្នកពិគ្រោះយោបល់

ឥរិយាបថជាវិជ្ជមានរបស់អ្នកពិគ្រោះយោបល់ចំពោះក្រុមគោលដៅមានសារៈសំខាន់ខ្លាំងណាស់ចំពោះការបង្កើតភាពជឿទុកចិត្តគ្នាទៅវិញទៅមក ដូច្នេះ វាគឺជាល័ក្ខខ័ណ្ឌដំបូងដើម្បីឱ្យការពិគ្រោះយោបល់ទទួលបានជោគជ័យ។ កំហុសមួយនៅក្នុងការអនុវត្តបច្ចេកទេសពិគ្រោះយោបល់អាចត្រូវបានអនុគ្រោះដោយក្រុមគោលដៅ ដរាបណាអ្នកពិគ្រោះយោបល់គោរពក្រុមគោលដៅរបស់ខ្លួន ទាំងក្នុងនាមបុគ្គល និងវិជ្ជាជីវៈ។ នេះមិនមែនមានន័យថាអ្នកពិគ្រោះយោបល់តែងតែត្រូវទទួលយក ឬ ឯកភាពទៅលើអ្វីៗទាំងអស់ដែលក្រុមគោលដៅគិត និងលើកឡើងនោះឡើយ។ ផ្ទុយទៅវិញ ជួនកាលវាក៏ជាការល្អដែរដែលអ្នកពិគ្រោះយោបល់ត្រូវជជែកវែកញែកជាមួយក្រុមគោលដៅ ដោយប្រើប្រាស់ឥរិយាបថប្រកបដោយការលើកទឹកចិត្ត ដើម្បីបំផុសគំនិតថ្មី។ យ៉ាងហោចណាស់ អ្នកពិគ្រោះយោបល់អាចរក្សាទំនាក់ទំនងល្អ និងរក្សាការជជែកពិភាក្សាប្រកបដោយអត្ថន័យជាមួយក្រុមគោលដៅ ដោយផ្អែកលើទស្សនៈរបស់ពួកគេ។ ដូច្នេះ ការគាំទ្ររបស់អ្នកពិគ្រោះយោបល់ប្រហែលជានឹងត្រូវបានស្វាគមន៍ស្ទើរតែគ្រប់ពេលទាំងអស់ពីសំណាក់ក្រុមគោលដៅ។

ឥរិយាបថសំខាន់ៗរបស់អ្នកពិគ្រោះយោបល់រួមមាន ៖

- **ត្រូវមានសង្គតិភាព** ៖ (=) "បង្ហាញពីភាពពូកែធ្វើ មិនគ្រាន់តែពូកែនិយាយ" ពោលគឺ ធ្វើខ្លួនជាគំរូសម្រាប់ក្រុមគោលដៅ។ វាមិនល្អនោះទេប្រសិនបើអ្នកពិគ្រោះយោបល់មិនជឿលើអ្វីដែលគាត់ប្រាប់ក្រុមគោលដៅ ឬ ប្រសិនបើគាត់ធ្វើផ្ទុយពីអ្វីដែលគាត់ប្រាប់ដល់ក្រុមគោលដៅរបស់គាត់។
- **ត្រូវចេះលើកទឹកចិត្ត** ៖ អ្នកពិគ្រោះយោបល់គួរគោរពបុគ្គល ឬក្រុមគោលដៅ ដែលគាត់កំពុងពិគ្រោះយោបល់ជាមួយ។ ប្រសិនបើគាត់មិនអាចធ្វើដូច្នេះបាន ពេលនោះគាត់មិនគួរ

ព្យាយាមបន្តពិគ្រោះយោបល់ជាមួយបុគ្គល ឬ ក្រុមគោលដៅនោះទេ ពីព្រោះមិនយូរមិនឆាប់ក្រុមគោលដៅនឹងបាត់បង់ជំនឿ។

- **ត្រូវច្បាស់លាស់អំពីតួនាទី** ៖ ប្រសិនបើអ្នកពិគ្រោះយោបល់ចង់ណែនាំដល់ក្រុមគោលដៅ ឬគាត់មានជំហរច្បាស់អំពីអ្វីមួយ គាត់គួរបើកចំហអំពីរឿងនោះ។ អ្នកពិគ្រោះយោបល់មិនគួរមានការលាក់បាំងឡើយ ពីព្រោះការធ្វើដូច្នេះមិនយូរមិនឆាប់គេនឹងដឹង និងធ្វើឲ្យបាត់បង់ជំនឿទុកចិត្តជាមួយក្រុមគោលដៅ។
- **ជៀសវាងសំណួរនាំមុខ** ៖ បើកចំហទទួលយកគំនិតរបស់ក្រុមគោលដៅ និងកុំបង្ហាញតម្រុយដោយព្យាយាមបង្ខំឲ្យគេទទួលយកគំនិតរបស់អ្នក ឧទាហរណ៍ដូចជាសំណួរ៖ "អ្នកក៏គិតផងដែរថា...មិនអញ្ចឹង?" ឬ "នេះគឺជា... មិនអញ្ចឹង?"។
- **បង្កើតទំនុកចិត្តជាមួយក្រុមគោលដៅ** ៖ ឥរិយាបថចេះឱ្យតម្លៃរបស់អ្នកពិគ្រោះយោបល់មានសារៈសំខាន់ដើម្បីកសាងទំនុកចិត្ត និងទំនាក់ទំនងជិតស្និទ្ធជាមួយក្រុមគោលដៅ។ ក្រុមគោលដៅនឹងមិនបង្ហាញបញ្ហារបស់ពួកគេទេ នៅពេលពួកគេគ្មានទំនុកចិត្ត។
- **ឱ្យតម្លៃដល់ចំណេះដឹង គំនិត និងបទពិសោធន៍របស់ក្រុមគោលដៅ** ៖ តាមរយៈដំណើរការប្រឹក្សាយោបល់ ក្រុមគោលដៅអាចមានជម្រើសល្អ ក្នុងការដោះស្រាយបញ្ហាដោយខ្លួនគាត់។ អ្នកពិគ្រោះយោបល់ត្រូវទទួលស្គាល់ចំណេះដឹង គំនិត និងបទពិសោធន៍របស់ក្រុមគោលដៅ ពីព្រោះក្រុមគោលដៅគឺជាអ្នកដែលត្រូវអនុវត្តជម្រើសទាំងនោះ។
- **ជួយក្រុមគោលដៅបង្កើតទំនុកចិត្តលើខ្លួនឯងដោយរៀនជំនាញថ្មី៖** អ្នកពិគ្រោះយោបល់សួរសំណួរនានាដើម្បីជួយក្រុមគោលដៅមើលឃើញពីទស្សនៈថ្មី និងបង្កើតជាជម្រើសដើម្បីកែលម្អស្ថានភាពរបស់ពួកគាត់ទាំងការបំពេញការងារ និងជំនាញវិជ្ជាជីវៈ។
- **ត្រូវទទួលខុសត្រូវលើដំណើរការជជែកពិភាក្សា៖** ការពិគ្រោះយោបល់ត្រូវផ្ដោតលើដំណើរការជជែកពិភាក្សា ដើម្បីជួយក្រុមគោលដៅបង្កើតនូវជម្រើសនានាដើម្បីដោះស្រាយបញ្ហារបស់ពួកគាត់។
- **មិនត្រូវណែនាំក្រុមគោលដៅឆ្ពោះទៅរកគំនិតគិតទុកជាមុនរបស់អ្នក៖** អ្នកពិគ្រោះយោបល់គួរជៀសវាងណែនាំក្រុមគោលដៅទៅរករបៀបវារៈដែលខ្លួនបានកំណត់ទុកជាមុន។ វគ្គពិគ្រោះយោបល់គួរត្រូវបានធ្វើឡើងដោយផ្អែកលើបញ្ហាដែលបានលើកឡើងដោយក្រុមគោលដៅ។

## ៣. ការផ្តល់ប្រឹក្សាបច្ចេកទេស ( Expert Advice ) ការពិគ្រោះយោបល់ ( Coaching ) និង ការបង្ហាត់បង្ហាញ ( Mentoring )

### ក. ការផ្តល់ប្រឹក្សាបច្ចេកទេស ( Expert Advice/Subject Matter Advice )

អ្នកប្រឹក្សាយោបល់ ឬ ទីប្រឹក្សាដើរតួនាទីជាអ្នកជំនាញ។ បន្ទាប់ពីដំណាក់កាលវិភាគមក អ្នកប្រឹក្សាយោបល់ធ្វើពង្រាងដំណោះស្រាយសមស្របមួយដោយផ្អែកលើជំនាញ និងចំណេះដឹងរបស់ខ្លួន។ បន្ទាប់មក អតិថិជននឹងត្រូវបានរំពឹងថាធ្វើតាមយោបល់របស់អ្នកជំនាញ ដើម្បីកែលម្អស្ថានភាពរបស់ខ្លួន។ អ្នកប្រឹក្សាយោបល់ អនុវត្តភារកិច្ចរបស់គាត់ ដោយផ្អែកលើល័ក្ខខ័ណ្ឌការងារ ដែលបានកំណត់ដោយអតិថិជន។ អ្នកប្រឹក្សាយោបល់គ្រប់គ្រងដំណើរការនៃការដោះស្រាយបញ្ហា ដោយស្នើឡើងនូវដំណោះស្រាយម្តងហើយម្តងទៀត និងផ្តល់ការគាំទ្រជំនាញបច្ចេកទេសដល់អតិថិជន។ ដំណោះស្រាយដែលបានស្នើឡើងអាចត្រូវបានកំណត់ត្រឹមសំណូមពរនៅក្នុងក្របខ័ណ្ឌនៃដំណើរការដោះស្រាយបញ្ហារបស់អតិថិជន។ ទោះបីជាយ៉ាងណាក៏ដោយ ដំណោះស្រាយទាំងនេះអាចជាផ្នែកមួយនៃដំណើរការពីលើចុះក្រោម ឬ ពីក្រោមទៅលើ ដែលក្នុងនោះអ្នកផ្តល់ប្រឹក្សាបច្ចេកទេសផ្តល់ដំណោះស្រាយបញ្ហា"ពីខាងលើ" និងក្នុងពេលជាមួយគ្នានោះគាំទ្រដល់អតិថិជននៅក្នុងការសម្រប ប្រកាន់យក និងអនុវត្តដំណោះស្រាយដែលបានស្នើឡើង"ពីខាងក្រោម"។ គោលដៅគឺដើម្បីផ្តល់ធាតុចូល ឬ សេវាដើម្បីជួយអតិថិជនសម្រេចបានលទ្ធផលរំពឹងទុកនៃកិច្ចការ ឬ គម្រោង សូម្បីតែគ្មានវត្តមានរបស់អ្នកផ្តល់យោបល់បច្ចេកទេសក៏ដោយ។

### ខ. ការពិគ្រោះយោបល់ ( Coaching )

អ្នកពិគ្រោះយោបល់សម្របសម្រួលដំណើរការដោះស្រាយបញ្ហា ដោយជួយក្រុមគោលដៅឲ្យធ្វើការទៅលើបញ្ហាដោយឯករាជ្យ និងបង្កើតដំណោះស្រាយដោយខ្លួនឯង។ អ្នកពិគ្រោះយោបល់យកចិត្តទុកដាក់ជាចម្បងទៅលើវិធីនៃការដោះស្រាយបញ្ហារបស់ក្រុមគោលដៅ (បញ្ហា និងកិច្ចការដែលត្រូវធ្វើដើម្បីឱ្យមានការផ្លាស់ប្តូរ) ដោយហេតុថាអ្វីដែលសំខាន់គឺក្រុមគោលដៅមានសមត្ថភាពដោះស្រាយបញ្ហាដោយខ្លួនឯង។ នៅក្នុងការពិគ្រោះយោបល់ លទ្ធផលក៏ដូចជាដំណើរការ គឺជាការទទួលខុសត្រូវរបស់ក្រុមគោលដៅ។

### គ. ការបង្ហាត់បង្ហាញ ( Mentoring )

អ្នកបង្ហាត់បង្ហាញ (Mentor) យកចិត្តទុកដាក់ជាចម្បងលើការអភិវឌ្ឍរបស់អតិថិជន។ យោងតាមលោក អ៊ិរិក ផាស្លូ (Eric Parsloe) នៃសាលាពិគ្រោះយោបល់ និងបង្ហាត់បង្ហាញអកស្វ៊ដ (The Oxford School of Coaching & Mentoring), *"ការបង្ហាត់បង្ហាញ (Mentoring) គឺដើម្បីគាំទ្រ និងលើកទឹកចិត្តដល់មនុស្សក្នុងការគ្រប់គ្រងការសិក្សាផ្ទាល់របស់ពួកគេ ក្នុងគោលបំណងដើម្បី*

*ឲ្យពួកគេអាចបង្កើនសក្តានុពលជាអតិបរមា អភិវឌ្ឍជំនាញ កែលម្អការអនុវត្តការងាររបស់ខ្លួន និងក្លាយខ្លួនជាមនុស្សដែលពួកគេចង់បាន*[2]។ វាគឺជាទំនាក់ទំនងមួយ មិនត្រឹមតែជានីតិវិធី ឬសកម្មភាពមួយប៉ុណ្ណោះទេ ដែលមនុស្សម្នាក់ជួយដល់ការអភិវឌ្ឍអាជីពរបស់មនុស្សម្នាក់ទៀតប្រកបដោយវិជ្ជាជីវៈ មិនត្រឹមតែពីអ្នកគ្រប់គ្រងទៅបុគ្គលិកដែលនៅក្រោមបង្គាប់របស់ខ្លួន[3]។

ការបង្ហាត់បង្ហាញគឺជាការជជែកពិភាក្សាគ្នាជាគូរវាងអ្នកដែលមានបទពិសោធន៍ ឬ ជំនាញច្រើនជាងជាមួយអ្នកមានបទពិសោធន៍ ឬ ជំនាញតិចជាងដោយមានការឯកភាពលើគោលបំណងឱ្យអ្នកដែលមានបទពិសោធន៍តិចមានការលូតលាស់ និងអភិវឌ្ឍជំនាញជាក់លាក់។

រូបភាពខាងក្រោមនេះបង្ហាញពីកម្រិតផ្សេងៗនៃការពិគ្រោះយោបល់ដែលផ្តោតលើដំណើរការ និងការផ្តល់ប្រឹក្សាបច្ចេកទេស ដើម្បីដោះស្រាយបញ្ហាសម្រាប់ក្រុមគោលដៅ:




[2] http://www.mentorset.org.uk/pages/mentoring.htm
[3] S Mind, 'Business Mentoring and Coaching', *Training and Development*, April 1993, p 26. *(www.experiencepays.qld.gov.au/pdf/eii/epas/retain/mentoring.pdf)*

## ៤. ចរិតលក្ខណៈនៃការផ្តល់ប្រឹក្សាបច្ចេកទេស និងការពិគ្រោះយោបល់

ការបែងចែកភាពខុសគ្នារវាងការផ្តល់ប្រឹក្សាបច្ចេកទេស និងការពិគ្រោះយោបល់គឺជាលំហាត់ដ៏មានប្រយោជន៍មួយសម្រាប់អ្នកពិគ្រោះយោបល់ ដើម្បីបំភ្លឺពីគោលបំណងជាមួយក្រុមគោលដៅ និងសម្របសម្រួលការគាំទ្រ។ អ្នកពិគ្រោះយោបល់អាចបំពេញតួនាទីទាំងពីរនៅក្នុងវិសាលភាពនៃការអនុវត្តគម្រោង ឬ កិច្ចព្រមព្រៀងមួយ។ នៅក្នុងករណីនេះ គេត្រូវជានាតម្លាភាពនៃតួនាទី។

| ទិដ្ឋភាពខុសគ្នា | ការផ្តល់ប្រឹក្សាបច្ចេកទេស | ការពិគ្រោះយោបល់ |
|---|---|---|
| លទ្ធផល | បញ្ហារបស់អតិថិជនត្រូវបានដោះស្រាយ | សមត្ថភាពរបស់ក្រុមគោលដៅក្នុងការដោះស្រាយបញ្ហាត្រូវបានអភិវឌ្ឍ |
| ការទទួលខុសត្រូវលើលទ្ធផល | ពឹងផ្អែកលើអ្នកផ្តល់ប្រឹក្សាបច្ចេកទេស | ពឹងផ្អែកលើក្រុមគោលដៅទាំងស្រុង |
| នីតិវិធីដើម្បីសម្រេចលទ្ធផល | -អ្នកផ្តល់ប្រឹក្សាបច្ចេកទេសអនុវត្តការងារយោងទៅលើល័ក្ខខ័ណ្ឌការងារដែលព្រមព្រៀងរវាងអតិថិជន និងអ្នកផ្តល់ប្រឹក្សាបច្ចេកទេស<br>-បង្កើត និងប្រគល់លទ្ធផលការងារជូនអតិថិជន | -លទ្ធផលនឹងត្រូវបានបង្កើតដោយការពិភាក្សា និងផ្តួចផ្តើម រួមគ្នា<br>-ផ្លាស់ប្តូរទស្សនៈ និងវិធីសាស្រ្តក្នុងការគិត និងដោះស្រាយបញ្ហា |
| ការទទួលខុសត្រូវលើនីតិវិធី | ពឹងផ្អែកទាំងស្រុងលើទីប្រឹក្សាបច្ចេកទេស | -ពឹងផ្អែកលើក្រុមគោលដៅ<br>-នីតិវិធីត្រូវបានស្នើដោយអ្នកពិគ្រោះយោបល់ ដោយមានការជជែកពិភាក្សា និងព្រមព្រៀងជាមួយក្រុមគោលដៅ |
| ជំនាញ | អ្នកជំនាញក្នុងការធ្វើដើម្បីឆ្លើយតបនឹងលទ្ធផលដែលបានកំណត់ដោយអតិថិជន (WHAT) | អ្នកជំនាញក្នុងការផ្តល់របៀបបង្កើតជម្រើសផ្សេងៗក្នុងការដោះស្រាយបញ្ហា (HOW) |
| ឧទាហរណ៍នៃសេវាកម្ម | សេវាកម្មអាចជា ៖ ការសិក្សាស្រាវជ្រាវ ការវាយតម្លៃគម្រោង ការបង្កើតគម្រោងសំណើ ការសរសេរគោលនយោបាយ។ល។ | សេវាកម្មអាចជា ៖ ដំណើរការនៃការរៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់...។ល។ |
| ឧបករណ៍ | ការស្រាវជ្រាវ ការអង្កេត | ការបំភ្លឺអំពីគោលបំណង ការបំភ្លឺអំពី |

| | | |
|---|---|---|
| | ការវិភាគឯកសារ | តួនាទី បច្ចេកទេសសួរសំណួរ ការបង្កើតសម្មតិកម្ម ព័ត៌មានត្រឡប់ |
| សំណើរបស់អ្នកពិគ្រោះយោបល់ | "ខ្ញុំសូមផ្តល់ដល់អ្នកនូវសំណើដំណោះស្រាយ ដែលឆ្លើយតបនឹងតម្រូវការជាក់លាក់របស់អ្នក" | "ខ្ញុំផ្តល់ដល់អ្នកនូវការគាំទ្រផ្នែកវិធីសាស្ត្រសមស្របសម្រាប់អនុវត្តក្នុងដំណើរការនៃការ ផ្លាស់ប្តូររបស់អ្នក" |

## ៥. ការបញ្ជាក់តួនាទីសម្រាប់អ្នកពិគ្រោះយោបល់

### ក. ទាក់ទងទៅនឹងពាក្យ "តួនាទី"

ពាក្យថា "តួនាទី" មានប្រភពដើមរបស់វានៅក្នុងសង្គមវិជ្ជា។ នៅក្នុងភាសារាល់ថ្ងៃ ពាក្យថា "តួនាទី" ត្រូវបានគេប្រើប្រាស់ដើម្បីរៀបរាប់ពីក្របខ័ណ្ឌការងារមួយរបស់យើង។ មនុស្សម្នាក់ទទួលយកដោយស្ម័គ្រចិត្ត ឬ ឯកឯងនូវតួនាទីមួយ ហើយត្រូវតែប្រតិបត្តិតាមវិធីជាក់លាក់ណាមួយនៅក្នុងក្របខ័ណ្ឌនៃតួនាទីនេះ។

ជាក់ស្តែង យើងបំពេញតួនាទីផ្សេងៗគ្នានៅក្នុងជីវិតវិជ្ជាជីវៈនិងឯកជនរបស់យើង។ តួនាទីមិនត្រូវបានកំណត់ដោយឡែក និងដោយសត្យានុម័តឡើយ ប៉ុន្តែវាកើតចេញពីការរៀបរាប់អំពីក្តីរំពឹងទុកជាក់លាក់។

ដូច្នេះ តួនាទីអាចត្រូវបានចាត់ទុកថាជាវិធីសាស្ត្រនៃការប្រព្រឹត្ត និងឥរិយាបថរបស់អ្នកកាន់តួនាទី។ តួនាទីត្រូវបានគេកំណត់ន័យជាលើកដំបូងតាមរយៈការរៀបរាប់ពីខាងក្រៅ។ តាមពិតគឺអ្នកដទៃទៀត (អ្នកបញ្ចូនតួនាទី) ដែលរំពឹងចង់បានអ្វីមួយពីអ្នកកាន់តួនាទី។

នៅពេលនេះ វាច្បាស់ណាស់ដែលថា ភាពមិនចុះសម្រុង (ទាក់ទងទៅនឹងទំនាស់នៃតួនាទី) ត្រូវបានរៀបចំជាមុនជាមួយនឹងការទទួលយកនូវតួនាទី។ តួនាទីរបស់គ្រូ គឺប្រហែលជាត្រូវបានកំណត់ខុសៗគ្នានៅចំពោះមុខក្រសែភ្នែករបស់នាយកសាលា និងក្រសែភ្នែករបស់សិស្ស ហើយការរំពឹងទុករបស់ឪពុកម្តាយអាចខុសគ្នាពីនេះនៅក្នុងទិដ្ឋភាពខ្លះ។ បន្ថែមពីលើនេះ វាគឺការស្វែងយល់របស់អ្នកកាន់តួនាទីអំពីតួនាទីនោះ។ ដូច្នេះ ការបញ្ជាក់ពីតួនាទីគឺជាធាតុមួយដែលមិនអាចខ្វះបាននៃសកម្មភាពតួនាទីប្រកបដោយមនសិកា។

ទោះបីជាយ៉ាងណាក្តី ទស្សនៈរបស់បុគ្គលផ្សេងៗអំពីបុគ្គលម្នាក់ដែលមានតួនាទីដូចគ្នាអាចនាំទៅរកការរំពឹងទុកខុសៗគ្នា។ បញ្ហាតែមួយអាចត្រូវបានគេយល់ឃើញខុសៗគ្នាអាស្រ័យលើតួនាទីដែលគេទទួលខុសត្រូវ។ ដូច្នេះ បុគ្គលម្នាក់អាចពាក់ព័ន្ធខុសគ្នាទាំងស្រុងទៅនឹងបញ្ហានៃការកាត់បន្ថយការងារនៅក្នុងអង្គការរបស់គាត់ អាស្រ័យលើថាតើគាត់ពាក់ព័ន្ធនៅក្នុងតួនាទីរបស់ប្រធានផ្នែក

បុគ្គលិកដែលពាក់ព័ន្ធ អ្នកឯកទេសខាងធនធានមនុស្សដែលទទួលខុសត្រូវ ឬសមាជិកក្រុមប្រឹក្សាការងារឬទេ។

យើងមានតួនាទីទាំងក្នុងបរិបទវិជ្ជាជីវៈ និងឯកជន ។ ទោះបីជាយ៉ាងណាក្តី ដោយសារតែតួនាទីមិនត្រូវបានកំណត់ជាសត្យានុម័ត ប៉ុន្តែត្រូវបានបង្កើតឡើងដោយមនុស្ស ការបញ្ជាក់តួនាទី និងតួនាទីដែលបានកំណត់នៅក្នុងកិច្ចសន្យា គឺជាធាតុដ៏សំខាន់មួយនៃការបំពេញវិជ្ជាជីវៈ។

ទាក់ទងទៅនឹងតួនាទីអ្នកពិគ្រោះយោបល់ ផ្នែកទាំងឡាយខាងក្រោមនេះគឺជាលទ្ធផលនៃការបញ្ជាក់៖

- តើអ្នកណាមានការរំពឹងទុកអ្វីខ្លះអំពីតួនាទីរបស់ខ្ញុំជាអ្នកពិគ្រោះយោបល់? (ការរំពឹងទុក "ត្រូវតែ" "គួរ" "អាច")
- តើខ្ញុំមានការរំពឹងទុកអ្វីខ្លះអំពីតួនាទីរបស់ខ្ញុំជាអ្នកពិគ្រោះយោបល់ម្នាក់?

## ២. សារៈសំខាន់នៃការយល់អំពីតួនាទីសម្រាប់ការពិគ្រោះយោបល់ និងការងារផ្តល់ប្រឹក្សា

ការសន្និដ្ឋានចំនួនបួនធំៗអាចធ្វើឡើងសម្រាប់បំពេញតួនាទីជំនាញវិជ្ជាជីវៈ៖

- **ការយល់ដឹងអំពីតួនាទី**

  ភាពច្បាស់លាស់អំពីការកំណត់តួនាទី ការយល់ដឹងអំពីភាពផ្សេងៗគ្នានៃតួនាទីដែលបានកំណត់ និងការដឹងអំពីការពណ៌នានៃតួនាទីផ្ទាល់ខ្លួន គឺជាបុរេល័ក្ខខ័ណ្ឌដើម្បីអាចទទួលយក ប្រើប្រាស់ និងផ្លាស់ប្តូរតួនាទីប្រកបដោយមនសិកា។

- **ការអនុវត្តតួនាទីប្រកបដោយតម្លាភាព**

  ការអនុវត្តតួនាទីជាមូលដ្ឋានសម្រាប់សកម្មភាពនានាឱ្យមានតម្លាភាពចំពោះខ្លួនឯង និងចំពោះអ្នកដទៃ ជួយសម្របសម្រួលដោយយកចិត្តទុកដាក់ខ្ពស់ និងជំរុញឱ្យមានការទទួលយក។ វាជាការចាំបាច់ដែលត្រូវផ្តល់តួនាទីដែលកំណត់ពីសកម្មភាពប្រកបដោយតម្លាភាព ជាពិសេសដោយសារតែការពិតដែលថាសកម្មភាពរបស់មនុស្សម្នាក់ ច្រើនតែចេញពីតួនាទីមួយចំនួន។

- **ការបញ្ជាក់ពីតួនាទី**

  តួនាទី ការរំពឹងទុក និងវិធីនៃការប្រព្រឹត្តដែលពាក់ព័ន្ធត្រូវតែបញ្ជាក់ឲ្យបានច្បាស់។ ជារឿយៗអាចនឹងមានទំនាស់នឹងគ្នានៅពេលមានការរំពឹងទុកផ្សេងៗគ្នាចំពោះការប្រើប្រាស់តួនាទីរបស់អ្នកពិគ្រោះយោបល់ ឬ តួនាទីរបស់ទីប្រឹក្សា។ អតិថិជនអាចគិតថា ទីប្រឹក្សាគួរ"ធ្វើការងារ" ខណៈពេលដែលទីប្រឹក្សាមានទស្សនៈផ្ទុយពីនេះ។ ការបញ្ជាក់ពីតួនាទី និងការពិនិត្យឡើងវិញ មិនមែនជាសកម្មភាពតែមួយដងចប់នោះទេ ប៉ុន្តែត្រូវតែធ្វើឡើងវិញនៅតាមពេលវេលាណាមួយ ដើម្បីទប់ស្កាត់ទំនាស់ខាងតួនាទីមិនឲ្យកើតឡើង។

- **ការចរចាអំពីតួនាទី**

ភាពចម្រុះនៃតួនាទីដែលត្រូវទទួលយក និងការរំពឹងទុកខុសៗគ្នា និងផ្ទុយគ្នាធ្វើឲ្យទំនាស់តួនាទីមិនអាចជៀសវាងបាន។ ការរំពឹងទុកឆ្ពោះទៅរកតួនាទី និងវិធីនៃការអនុវត្តតួនាទីមួយ មិនចាំបាច់ត្រូវតែទទួលយក និងអនុវត្តនោះឡើយ។ នៅទីណាដែលការប្រើប្រាស់តួនាទីធ្វើឱ្យមានទំនាស់ជាមួយការរំពឹងទុក ចំពោះតួនាទីដូចគ្នា ឬ តួនាទីរបស់អ្នកដទៃទៀត បញ្ហានេះគួរតែត្រូវបានចរចាគ្នា។

## គ. តួនាទីនៃការពិគ្រោះយោបល់នៅក្នុងការងារវិមជ្ឈការ

អ្នកពិគ្រោះយោបល់ដែលធ្វើការនៅក្នុងបរិបទវិមជ្ឈការនៅក្នុងប្រទេសកម្ពុជាប្រហែលជានឹងមិនមានតួនាទីដូចគ្នានឹងអ្នកពិគ្រោះយោបល់ក្នុងបរិបទមួយផ្សេងទៀត ដែលក្រុមគោលដៅមានរឿងរ៉ាវ ឬ បញ្ហាត្រូវដោះស្រាយ ហើយអ្នកពិគ្រោះយោបល់ត្រូវបានស្នើឲ្យជួយអតិថិជនបង្កើតនូវដំណោះស្រាយ ឬ ជម្រើសសម្រាប់រឿងរ៉ាវ ឬ បញ្ហានេះ។ អ្នកពិគ្រោះយោបល់នៅក្នុងបរិបទកម្ពុជានឹងមានតួនាទីខុសៗគ្នា។ ដូច្នេះ តើអ្វីទៅដែលជាផ្នែកមួយនៃតួនាទីនៃការពិគ្រោះយោបល់? តើមានតួនាទីអ្វីផ្សេងទៀត?

អ្នកសម្របសម្រួលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប នៅថ្នាក់ខេត្ត និងស្រុក នឹងត្រូវរំពឹងថានឹងដើរតួនាទីផ្សេងៗគ្នានៅក្នុងពេលតែមួយ។ ពួកគេគឺជាអ្នកផ្តល់ជំនាញបច្ចេកទេស និងផ្តល់ប្រឹក្សាក្នុងពេលធ្វើការងារ ហើយម្យ៉ាងទៀតពួកគេត្រូវបានរំពឹងថានឹងធ្វើការជាអ្នកពិគ្រោះយោបល់សម្រាប់បុគ្គល និងជាអ្នកសម្របសម្រួលសម្រាប់ក្រុម ដោយពួកគេគួរជួយអតិថិជន ឬ ក្រុមគោលដៅក្នុងការបង្កើតដំណោះស្រាយដោយខ្លួនឯង។ វាគឺជាកត្តាប្រឈមមួយដែលពួកគេនឹងជួបប្រទះជាបន្តបន្ទាប់ ក្នុងការសម្រេចថាតើតួនាទីមួយណាដែលពួកគេត្រូវបំពេញ។ តើពេលណាពួកគេត្រូវមានគំនិតផ្តួចផ្តើម និង"អង្គុយលើកៅអីអ្នកបើកបរ"? ហើយតើនៅពេលណាដែលពួកគេនឹងជួយសម្របសម្រួលក្នុងការបង្កើតដំណោះស្រាយសម្រាប់អតិថិជន ឬ ក្រុមគោលដៅរបស់ពួកគេដែលជាអ្នកទទួលខុសត្រូវ និង"អង្គុយលើកៅអីអ្នកបើកបរ"? ការបញ្ជាក់តួនាទី គឺជាដំណើរការបន្តបន្ទាប់មួយ (មើលខាងលើ)។

ដើម្បីបញ្ជាក់ថាតួនាទីពិគ្រោះយោបល់ ឬ តួនាទីវិជ្ជាជីវៈមានការពាក់ព័ន្ធ គេគួរធ្វើការបែងចែកពីភាពខុសគ្នា។ លក្ខណៈវិនិច្ឆ័យសម្រាប់បែងចែកភាពខុសគ្នា គឺការញែកឱ្យដាច់ពីគ្នា នៃការអន្តរាគមន៍របស់អ្នកពិគ្រោះយោបល់ ដោយយោងតាមកម្រិតនៃការបង្គាប់បញ្ជា។

ដ្យាក្រាមខាងក្រោម (រូបភាពទី៣) បង្ហាញពីតួនាទីនានា ដោយយោងតាមកម្រិតបង្គាប់បញ្ជាក្នុងតួនាទីរបស់អ្នកពិគ្រោះយោបល់ ឬ អ្នកផ្តល់ប្រឹក្សា។

កាលណាតួនាទីស្ថិតនៅក្នុងផ្នែកខាងឆ្វេងនៃជ្យាក្រាមកាន់តែខ្លាំង អ្នកពិគ្រោះយោបល់កាន់តែមិនមានលក្ខណៈបង្គាប់បញ្ជា ដោយពួកគេផ្តល់នូវរបៀប ឬ វិធីសាស្ត្រដើម្បីគាំទ្រដល់ដំណើរការដោះស្រាយបញ្ហារបស់អតិថិជន ឬ ក្រុមគោលដៅ។ ឥរិយាបថជាមូលដ្ឋានរបស់អ្នកប្រឹក្សាយោបល់ចំពោះអតិថិជន ឬ ក្រុមគោលដៅគឺ៖ "អ្នកពិតជាមានសមត្ថភាពទាំងអស់ យើងគ្រាន់តែលុបបំបាត់ឧបសគ្គដើម្បីប្រើប្រាស់វាដោយមានប្រយោជន៍ប៉ុណ្ណោះ"។ ឆ្លើយតបនឹងអំណះអំណាងខាងលើនេះ ឥរិយាបថ ជាមូលដ្ឋានរបស់អតិថិជន ឬ ក្រុមគោលដៅគឺ៖ "ជួយខ្ញុំឲ្យមើលផ្លូវកាន់តែច្បាស់ផង និងអភិវឌ្ឍសមត្ថភាពដែល ចាំបាច់"។

នៅផ្នែកខាងស្តាំបំផុត អ្នកផ្តល់ប្រឹក្សា គឺជាអ្នកដោះស្រាយបញ្ហា។ ឥរិយាបថជាមូលដ្ឋានរបស់អ្នកផ្តល់ប្រឹក្សា អាចត្រូវបានពិពណ៌នាដូចខាងក្រោម ៖ "ខ្ញុំដឹងអ្វីដែលល្អសម្រាប់អ្នក"។ ឥរិយាបថដូចគ្នាសម្រាប់អតិថិជន ឬ ក្រុមគោលដៅគឺ ៖ "ផ្តល់ដល់ខ្ញុំនូវដំណោះស្រាយ ខ្ញុំនឹងធ្វើអ្វីតាមទាំងអស់ដែលអ្នកនិយាយ"។ គុណវិបត្តិធំគឺថា តាមរយៈតួនាទីដោះស្រាយបញ្ហារបស់ទីប្រឹក្សា សមត្ថភាពរបស់អតិថិជន ឬក្រុមគោលដៅមិនត្រូវបានលើកកម្ពស់ពិតប្រាកដនោះទេ។ ប្រហែលជាភាគច្រើនបំផុត អតិថិជន ឬ ក្រុមគោលដៅនឹងត្រូវការជំនួយពីអ្នកពិគ្រោះយោបល់ម្តងទៀតនៅពេលមានបញ្ហាកើតឡើងម្តងទៀត។

តួនាទី និងតួនាទីអន្តរកាល មិនតែងតែច្បាស់លាស់ដាច់ខាតនោះទេ ហើយនៅក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍ តួនាទីទាំងអស់ត្រូវបានគេអំពាវនាវរកជារឿយៗ។ សម្រាប់សកម្មភាពប្រឹក្សាយោបល់ដែលមានប្រសិទ្ធភាព សំខាន់ត្រូវគិតទុកជាមុនអំពីតួនាទីតាមរយៈសកម្មភាពស្តែងចេញរបស់នរណាម្នាក់ និងជ្រើសរើស ឬ បង្កើតឧបករណ៍ទាំងឡាយដែលមានប្រយោជន៍សម្រាប់តួនាទីនេះ។



រូបភាពទី៣៖ វិសាលភាពនៃតួនាទីរបស់ការពិគ្រោះយោបល់

## ឃ. តួនាទីផ្សេងៗនៃការផ្តល់ប្រឹក្សា

| | |
|---|---|
| អ្នកពិគ្រោះយោបល់ (Coach) | ជួយដោយផ្តោតលើតម្រូវការ។ ផ្តល់ព័ត៌មានត្រឡប់ដល់អតិថិជន ឬ ក្រុមគោលដៅ ហើយអាចបង្កើតជម្រើសរួមគ្នាជាមួយក្រុមគោលដៅ។ ផ្តោតលើការរីកចម្រើនរបស់អតិថិជន ឬ ក្រុមគោលដៅ ពាក់ព័ន្ធនឹងបញ្ហាវិជ្ជាជីវៈជាក់លាក់។ |
| អ្នកបង្ហាត់បង្ហាញ (Mentor) | ផ្តោតលើការរីកចម្រើនជាទូទៅរបស់អតិថិជន មិនសំដៅតែទៅលើការរីកចម្រើនខាងវិជ្ជាជីវៈប៉ុណ្ណោះទេ។ |
| អ្នកសម្របសម្រួល (Facilitator) | ជាទូទៅធ្វើការងារជាមួយក្រុម ដោយផ្តល់ការគាំទ្រខាងវិធីសាស្ត្រក្នុងការបំផុសគំនិត បង្កើតរបៀបវារៈ។ល។ មិនចាំបាច់មានជំនាញបច្ចេកទេសស៊ីជម្រៅទេ។ |
| គ្រូបង្គោល (Trainer) | យកចិត្តទុកដាក់លើការបំពេញការងារទូទៅ និងទ្រឹស្តី ជាជាងការអនុវត្តការងារជាក់ស្តែងក្នុងស្ថានភាពណាមួយ។ ចំណេះដឹងពី "ធ្មើរដាក់សៀវភៅ" ត្រូវបានផ្ទេរទៅសិក្ខាកាម ឬ អ្នកចូលរួម។ |
| អ្នកជំនាញការ/ទីប្រឹក្សាបច្ចេកទេស (Expert/Technical Advisor) | ផ្តោតលើលទ្ធផលគម្រោង និងមិនចាំបាច់ត្រូវតែចាប់អារម្មណ៍លើការរីកចម្រើនរបស់អតិថិជននោះទេ។ ជួយដោះស្រាយបញ្ហារបស់អតិថិជន ប៉ុន្តែអតិថិជននឹងអាចត្រូវការជំនួយពីអ្នកជំនាញម្តងទៀតនៅពេលក្រោយ។ |

## ៦. ជំនាញចាំបាច់សម្រាប់ការពិគ្រោះយោបល់

➢ ជំនាញសួរសំណួរ ៖ មានសារៈសំខាន់សម្រាប់ការពិគ្រោះយោបល់។ អ្នកពិគ្រោះយោបល់នឹងសួរសំណួរដើម្បីយល់ពីបរិបទពិតប្រាកដនៃស្ថានភាពរបស់ក្រុមគោលដៅ និងជួយក្រុមគោលដៅវាយតម្លៃបញ្ហា និងបង្កើតដំណោះស្រាយ។ នៅក្នុងវគ្គពិគ្រោះយោបល់ប្រភេទសំណួរទាំងឡាយខាងក្រោមនេះមានសារៈសំខាន់សម្រាប់ការពិគ្រោះយោបល់។

| ប្រភេទសំណួរ | សារៈសំខាន់ | ឧទាហរណ៍ |
|---|---|---|
| សំណួរអំពីបរិបទ | ផ្តល់ព័ត៌មានអំពីទិន្នន័យ/ហេតុការណ៍នៃស្ថានភាពជាក់ស្តែង | • "តើក្រុមគម្រោងរបស់អ្នកមាននិយោជិតប៉ុន្មាននាក់?"<br>• តើអ្នកជួបគ្នាញឹកញាប់ប៉ុណ្ណា?<br>• "តើអ្នកណាខ្លះចូលរួមក្នុងកិច្ចប្រជុំ?" |
| សំណួរដែលតម្រូវឱ្យមានការរៀញគ្នាឱ្យជាច់ | • បញ្ជាក់ភាពច្បាស់លាស់ទៅលើព័ត៌មានស្រពិចស្រពិល | • តើបញ្ហានេះមានទម្ងន់ចំពោះអ្នកណា?<br>• ចន្លោះពី ០ ទៅ ១០០ តើបញ្ហានេះមាន ទម្ងន់កម្រិតណា?<br>• "តើទស្សនៈរបស់សហសេវិកអ្នកខុសពី |

| | | |
|---|---|---|
| | | ដូចម្ដេច?" |
| សំណួរបែបសន្មត់ | • គិតចេញពីក្រៅពីបញ្ហា (ដោយយកបញ្ហាផ្សេងស្រដៀងគ្នាមកធ្វើការប្រៀបធៀប និងផលប៉ះពាល់) | • សន្មត់ថា...តើអ្វីជាលទ្ធផលបើសិនជាអ្នកធ្វើដូចនេះ?<br>• បើសិនជាអ្នកចង់ដោះស្រាយបញ្ហាទាំង ២នេះក្នុងពេលតែមួយ តើវាអាចធ្វើទៅបានដែរ ឬ ទេ? |
| សំណួរអំពីអនាគត | • ផ្ដោតការគិតដោយសម្លឹងមើលទៅអនាគត<br>• បង្កើតទិដ្ឋភាពវិជ្ជមានមួយនៅក្នុងស្ថានភាពលំបាក (ដោយបង្កើតទស្សនៈវិស័យមួយ) | • តើអ្វីជាការរំពឹងទុកសម្រាប់អ្នកបើសិនណាបញ្ហានេះត្រូវបានដោះស្រាយរួច?<br>• តើអ្នកចង់សម្រេចបានអ្វីក្នុងរយៈពេល២ឆ្នាំទៀត? |
| សំណួរប្ដូរទស្សនៈ | ប្ដូរទស្សនៈដោយយកការយល់ឃើញ និងការវាយតម្លៃរបស់អ្នកផ្សេងមកធ្វើការពិចារណា | • តើមិត្តរួមការងាររបស់អ្នកនឹងគិតយ៉ាងណានៅពេលអ្នក...?<br>• តើអ្នកយល់ថាប្រធានរបស់អ្នកនឹងផ្ដល់ដំណោះស្រាយជូនអ្នកដោយវិធីណា? |
| សំណួរអំពីឥរិយាបថ | • ដើម្បីដឹងពីជំហរពិតប្រាកដ (របស់ក្រុមគោលដៅ) | • តើលោក "ក" នឹងមានប្រតិកម្មបែបណាចំពោះសំណើរនេះ?<br>• តើអ្នកនឹងធ្វើយ៉ាងដូចម្ដេចវិញនៅពេលដែលក្រុមការងាររបស់អ្នកនៅទីនេះជុំគ្នា? |
| សំណួរស្ទាបស្ទង់<br>Gossip questions | ធ្វើឱ្យព័ត៌មាន ដែលលាក់ទុកបានបង្ហាញចេញមក(សូមគិតអំពីបរិបទ និងវប្បធម៌ក្នុងការប្រើសំណួរប្រភេទនេះ) | • រហូតមកទល់ពេលនេះពុំមានអ្នកណាម្នាក់បានដឹងច្បាស់នៅឡើយ តើអ្នកមានដឹងពាក្យចចាមអារាមអ្វីខ្លះដែរឬទេ?<br>• តើប្រជាពលរដ្ឋមាននិយាយអ្វីដែរ ឬទេចំពោះការចូលរួមបដិភាគក្នុងការធ្វើផ្លូវមួយខ្សែនេះ? |

➢ ជំនាញស្ដាប់ ៖ អ្នកពិគ្រោះយោបល់ត្រូវបង្ហាញជំនាញស្ដាប់ខ្ពស់ក្នុងកំឡុងពេលពិគ្រោះយោបល់។ ជំនាញស្ដាប់ជួយអ្នកពិគ្រោះយោបល់ ក្នុងការប្រមូលព័ត៌មានដែលពាក់ព័ន្ធទាំងអស់ដែលក្រុម គោលដៅលើកឡើង។

- **ជំនាញសង្ខេប** ៖ វាជាការសំខាន់ដែលអ្នកពិគ្រោះយោបល់ទាំងអស់ត្រូវធានាថា ការពិភាក្សាមិនចាកប្រធាន។ ដូច្នេះ អ្នកពិគ្រោះយោបល់មានតួនាទីធ្វើការសង្ខេបព័ត៌មានពាក់ព័ន្ធ និងធានាថាការពិភាក្សាផ្តោតទៅលើប្រធានបទនៃវគ្គពិគ្រោះយោបល់ ដើម្បីជៀសវាងការយល់ច្រឡំណាមួយក្នុងចំណោមក្រុមគោលដៅ។ ប្រសិនបើអ្នកពិគ្រោះយោបល់មិនសង្ខេបចំណុចសំខាន់ៗទេ ក្រុមគោលដៅពិបាកនឹងយល់ខ្លឹមសារ។
- **ជំនាញឆ្លុះបញ្ចាំង** ៖ នេះមានន័យថា អ្នកពិគ្រោះយោបល់ត្រូវឆ្លុះបញ្ចាំងពីការអនុវត្តការងាររបស់ខ្លួន និងការអនុវត្តការងាររបស់ក្រុមគោលដៅនៅក្នុងដំណើរការពិគ្រោះយោបល់ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវគុណភាពសម្រាប់ការពិគ្រោះយោបល់លើកក្រោយ។

## ៧. ដំណាក់កាលនៃការពិគ្រោះយោបល់

ក. ដំណាក់កាលទី១ ៖ ការកសាងទំនាក់ទំនង

***គោលបំណងនៃដំណាក់កាល ៖*** *អ្នកពិគ្រោះយោបល់ និងក្រុមគោលដៅបង្កើតទំនាក់ទំនងជាវិជ្ជមាន និងបរិយាកាសល្អសម្រាប់ការពិភាក្សា។*

***កិច្ចការដែលអ្នកពិគ្រោះយោបល់គួរធ្វើ ៖***

- *បង្កើតទំនាក់ទំនងជឿទុកចិត្តគ្នា និងបរិយាកាសល្អសម្រាប់ការពិភាក្សា ដោយសំដែងការស្វាគមន៍គ្នា និងបង្ហាញពីឥរិយាបថលើកទឹកចិត្ត (ជាងនេះទៅទៀត អ្នកពិគ្រោះយោបល់ត្រូវទទួលយកដោយគ្មានល័ក្ខខ័ណ្ឌ ដែលមានន័យថា ពួកគាត់ពុំមានការវិនិច្ឆ័យ និងវាយតម្លៃអំពីគំនិត អារម្មណ៍ និងឥរិយាបថរបស់ក្រុមគោលដៅ)*
- *រៀបចំឱ្យមានទីកន្លែង/បន្ទប់សមស្របសម្រាប់កិច្ចពិភាក្សាពិគ្រោះយោបល់*
- *បែងចែកពេលវេលាសម្រាប់កិច្ចពិភាក្សាពិគ្រោះយោបល់*
- *យកចិត្តទុកដាក់លើពាក្យគន្លឹះដែលក្រុមគោលដៅបាននិយាយ*
- *សំដែងការចាប់អារម្មណ៍ ការគោរព ការយល់ដឹង និងការយល់ចិត្ត។*

ខ. ដំណាក់កាលទី២ ៖ ការបញ្ជាក់ឱ្យច្បាស់ពីបញ្ហា/ស្ថានភាព

***គោលបំណងនៃដំណាក់កាល ៖*** *ក្រុមគោលដៅ និងអ្នកពិគ្រោះយោបល់មានទស្សនៈរួមអំពីស្ថានភាព ដែលទាក់ទងទៅនឹងវគ្គពិគ្រោះយោបល់ ៖*

***កិច្ចការដែលគួរធ្វើ ៖***

- *ស្វែងយល់អំពីស្ថានភាពទូទៅ បញ្ជាក់ពីស្ថានភាពចាប់ផ្តើម និងស្ថានភាពចុងក្រោយដែលចង់បាន ក្នុងចំណោមបញ្ហាដទៃទៀត។*
- *ស្វែងយល់ស៊ីជម្រៅពីបញ្ហាតាមរយៈការសួរសំណួរ និងរកឱ្យឃើញនូវបញ្ហាពិតប្រាកដរបស់ក្រុមគោលដៅ។*
- *ប្រៀបធៀបស្ថានភាព និងបញ្ហាពិគ្រោះយោបល់ក្នុងកំឡុងពេល និងក្រោយពេលស្តាប់ស្តង់៖ ទិដ្ឋភាព និងការយល់ឃើញថ្មីៗរបស់ក្រុមគោលដៅ ជារឿយៗកើតចេញពីការពិភាក្សារួមគ្នារវាងក្រុមគោលដៅ និងអ្នកពិគ្រោះយោបល់។ បញ្ហាជាក់ស្តែងរបស់ក្រុមគោលដៅ អាចខុសគ្នាពីបញ្ហាដែលបង្ហាញពីខាងដើម។*
- *ចំណាយពេលស្វែងយល់ពីបញ្ហា និងស្ថានភាពរបស់ក្រុមគោលដៅ*

គ. ដំណាក់កាលទី៣ ៖ ការព្រមព្រៀងលើគោលបំណង

***គោលបំណងនៃដំណាក់កាល ៖*** *ក្រុមគោលដៅ និងអ្នកពិគ្រោះយោបល់មានការយល់ដឹងដូចគ្នាអំពីគោលបំណងនៃវគ្គពិគ្រោះយោបល់។*

***កិច្ចការដែលគួរធ្វើ ៖***

- *កំណត់ឱ្យឃើញនូវការរំពឹងទុករបស់ក្រុមគោលដៅអំពីការពិគ្រោះយោបល់ជាគ្នា និងប្រៀបធៀបជាមួយលទ្ធភាពរបស់អ្នកពិគ្រោះយោបល់(តើខ្ញុំអាចធ្វើអ្វីបាន? តើខ្ញុំគួរធ្វើអ្វី? តើខ្ញុំចង់ធ្វើអ្វី?)។ ក្នុងករណីអ្នកពិគ្រោះយោបល់មិនអាចឆ្លើយតបនឹងការរំពឹងទុករបស់ក្រុមគោលដៅបាន គាត់គួរចរចាជាមួយក្រុមគោលដៅ ដើម្បីឯកភាពគ្នាលើការរំពឹងទុករួមមួយ។*
- *ធ្វើការព្រមព្រៀងគ្នាលើគោលបំណង និងនីតិវិធី*
- *កំណត់ក្របខ័ណ្ឌការងារ និងពេលវេលាដែលអាចអនុវត្តបាន ។*

ឃ. ដំណាក់កាលទី៤ ៖ ការស្វែងយល់ និងកំណត់ដំណោះស្រាយបញ្ហា

***គោលបំណងនៃដំណាក់កាល ៖*** *ដំណោះស្រាយដែលអាចរកឃើញថ្មីៗត្រូវបានបង្កើតឡើង និងទទួលយកដោយក្រុមគោលដៅ។*

***កិច្ចការដែលគួរធ្វើ ៖***

- *ស្វែងយល់ពីអ្វីដែលធ្លាប់បានធ្វើកន្លងមក ដើម្បីកែលម្អស្ថានភាព និង/ឬដោះស្រាយបញ្ហា*
- *បង្កើតជម្រើសថ្មីៗដោយប្រើប្រភេទសំណួរផ្សេងៗខាងលើ (ឧទាហរណ៍ សំណួរអំពីអនាគត សំណួរបែបសន្មត់ សំណួរប្តូរទស្សនៈ...។ល។)*
- *រៀនសូត្រពីបទពិសោធន៍ក្នុងការដោះស្រាយបញ្ហាស្រដៀងគ្នានៅកន្លែងផ្សេងៗ (ឧ. ការអនុវត្តល្អបំផុត...។ល។)*
- *បង្កើត និងវាយតម្លៃជម្រើសថ្មីៗ។*
- *វិភាគរកអ្នកដែលអាចជួយគាំទ្របាន*

ង. ដំណាក់កាលទី៥ ៖ សេចក្តីសន្និដ្ឋាន

***គោលបំណងនៃដំណាក់កាល ៖*** *លទ្ធផលនៃការពិគ្រោះយោបល់ត្រូវបានកត់ត្រា និងសម្រេចបានតាមរយៈកិច្ចព្រមព្រៀង។*

***កិច្ចការដែលគួរធ្វើ ៖***

- *សង្ខេបរួមគ្នានូវជម្រើស និងធ្វើការសម្រេចចិត្ត*
- *សួរពីជំហានបន្ទាប់ក្នុងការអនុវត្តសេចក្តីសម្រេចចិត្តដែលបានធ្វើឡើង*
- *ពិនិត្យរួមគ្នាលើការសម្រេចគោលបំណងដែលបានឯកភាព*
- *ឯកភាពគ្នាលើប្រធានបទសម្រាប់ការពិគ្រោះយោបល់លើកក្រោយរវាងអ្នកពិគ្រោះយោបល់ និងក្រុមគោលដៅ*
- *វាយតម្លៃលើដំណើរការពិគ្រោះយោបល់។*

## ៨. ដ្យាក្រាមនៃដំណើរការពិគ្រោះយោបល់

ដំណើរការពិគ្រោះយោបល់អាចត្រូវបានពន្យល់នៅក្នុងដ្យាក្រាមខាងលក្រោមដើម្បីបង្ហាញពីវិសាលភាព និងដែនកំណត់នៃដំណាក់កាលនីមួយៗក្នុងកំឡុងពេលពិភាក្សាពិគ្រោះយោបល់។




រូបភាពទី២ ៖ ដ្យាក្រាមនៃដំណើរការពិគ្រោះយោបល់

នៅក្នុងដំណាក់កាលទី១ អ្នកពិគ្រោះយោបល់កសាងទំនាក់ទំនង និងបង្កើតជាបរិយាកាសស្និទ្ធស្នាលជាមួយក្រុមគោលដៅ។ នៅក្នុងដំណាក់កាលទី២ អ្នកពិគ្រោះយោបល់ប្រើប្រភេទសំណួរផ្សេងៗ ជាពិសេសសំណួរអំពីបរិបទ ដើម្បីបង្កើនការយល់អំពីស្ថានភាពពិតរបស់ក្រុមគោលដៅ។ ដំណាក់កាលទី២ មានសារៈសំខាន់ខ្លាំងណាស់ ដើម្បីបំភ្លឺអំពីបញ្ហានានាដែល ក្រុមគោលដៅជួបប្រទះមុននឹងព្រមព្រៀងគ្នាលើគោលបំណងនៃវគ្គពិគ្រោះយោបល់ដែលត្រូវអនុវត្តនៅក្នុងដំណាក់កាលទី៣។ នៅក្នុងដំណាក់កាលទី៣ អ្នកពិគ្រោះយោបល់គួរកំណត់ ឬ បញ្ហាសំខាន់យកមកពិភាក្សា។ អ្នកពិគ្រោះយោបល់គួរបញ្ជាក់ពីការរំពឹងទុករបស់ក្រុមគោលដៅ និងឯកភាពលើគោលបំណង និងនីតិវិធីជាក់លាក់។ ប្រសិនបើកិច្ចព្រមព្រៀងមិនអាចសម្រេចបាន វគ្គពិគ្រោះយោបល់ត្រូវតែបញ្ឈប់។

នៅក្នុងដំណាក់កាលទី៤ អ្នកពិគ្រោះយោបល់ប្រើប្រភេទសំណួរផ្សេងៗ ដើម្បីជួយឱ្យក្រុមគោលដៅគិតវិភាគ បង្កើនឱកាសជាអតិបរមា ធ្លឹះសក្តានុពល និងបង្កើតទស្សនវិស័យថ្មីៗ ដែលក្រុមគោលដៅអាចប្រើជាជម្រើសក្នុងការដោះស្រាយបញ្ហាផ្ទាល់ខ្លួនរបស់ពួកគេ។

នៅក្នុងដំណាក់កាលទី៥ អ្នកពិគ្រោះយោបល់ និងក្រុមគោលដៅសង្ខេបជម្រើសរួមគ្នា។ ក្រុមគោលដៅធ្វើការសម្រេចចិត្តអនុវត្តជម្រើស និងឯកភាពលើផែនការសកម្មភាពនៅចុងបញ្ចប់នៃវគ្គពិគ្រោះយោបល់។

## ៩. ការបង្កើតកិច្ចតែងការអំពីការពិគ្រោះយោបល់

ជាទូទៅ កិច្ចពិភាក្សាពិគ្រោះយោបល់ គឺជាដំណើរការពិគ្រោះយោបល់មួយទល់នឹងមួយដោយមិនបានកំណត់របៀបវារៈជាមុនឡើយ។ ប្រធានបទសម្រាប់ការពិគ្រោះយោបល់បានមកពីការសួរសំណួរ និងការបំភ្លឺរវាងអ្នកពិគ្រោះយោបល់ និងក្រុមគោលដៅក្នុងពេលពិភាក្សា។ នៅក្នុងក្របខ័ណ្ឌនៃកម្មវិធី EU-SPACE, ការពិគ្រោះយោបល់ត្រូវបានគេធ្វើឡើងញឹកញាប់បំផុតជាមួយក្រុមគោលដៅជាក្រុម (សមាជិកក្រុមប្រឹក្សាទាំងអស់ ប្រធានក្រុមប្រឹក្សា គណៈអភិបាល នាយករដ្ឋបាល ។ល។)។ ដូច្នេះ កិច្ចការនេះតម្រូវឲ្យអ្នកពិគ្រោះយោបល់ ឬ អ្នកសម្របសម្រួលកែសម្រួលទស្សនាទាននៃការពិគ្រោះយោបល់សុទ្ធសាធខាងលើដើម្បីបន្សាំទៅនឹងបរិបទការងាររបស់ពួកគេ។ បន្ថែមពីលើនេះ អ្នកពិគ្រោះយោបល់ ឬ អ្នកសម្របសម្រួល គួររៀបចំកិច្ចតែងការដែលងាយយល់។

### ក. ទម្រង់សម្រាប់សង្កេតការពិគ្រោះយោបល់

មានទម្រង់សង្កេតការពិគ្រោះយោបល់ពីរសម្រាប់អ្នកពិគ្រោះយោបល់ប្រើ៖ ទម្រង់ទី១ប្រើបន្ទាប់ពីការពិគ្រោះយោបល់ និងទម្រង់ទី២ប្រើសម្រាប់សង្កេតការអនុវត្តរបស់ក្រុមគោលដៅ។ ទម្រង់ទាំងនេះជួយអ្នកពិគ្រោះយោបល់កំណត់ពីចំណុចខ្លាំង និងចំណុចខ្សោយនៃការអនុវត្តការងាររបស់ក្រុមគោលដៅ និងផ្តល់ព័ត៌មានត្រឡប់ដល់ក្រុមគោលដៅនៅក្នុងវគ្គពិគ្រោះយោបល់បន្ទាប់។

ទម្រង់ទី១ ៖ ទម្រង់សង្កេតការពិគ្រោះយោបល់បន្ទាប់ពីវគ្គនីមួយៗ (ត្រូវបំពេញដោយអ្នកពិគ្រោះយោបល់)

<table>
<tr><td colspan="4">ពិគ្រោះយោបល់អំពី</td></tr>
<tr><td colspan="2" rowspan="2">បំពេញដោយ</td><td colspan="2">កាលបរិច្ឆេទ</td></tr>
<tr><td colspan="2">ទីកន្លែង</td></tr>
<tr><td colspan="4">ក្រុមគោលដៅ</td></tr>
<tr><td>ចំនួនក្រុមប្រឹក្សា<br>☐ ខេត្ត<br>☐ ក្រុង<br>☐ ស្រុក<br>សរុប....................<br>ស្រី....................</td><td colspan="2">គណៈអភិបាល<br>☐ ខេត្ត<br>☐ ក្រុង<br>☐ ស្រុក<br>សរុប..........................<br>ស្រី..........................</td><td>☐ នាយករដ្ឋបាល<br>☐ នាយករងរដ្ឋបាល<br>☐ បុគ្គលិករដ្ឋបាល<br>សរុប..........................<br>ស្រី..........................</td></tr>
<tr><td colspan="4">ចូរសរសេរដោយកាសង្ខេបពីការសង្កេតនៃកិច្ចប្រជុំក្រុមប្រឹក្សា:</td></tr>
<tr><td colspan="2">ចំណុចល្អរបស់ក្រុមគោលដៅ</td><td colspan="2">ចំណុចដែលគួរកែលម្អរបស់ក្រុមគោលដៅ</td></tr>
<tr><td colspan="2"></td><td colspan="2"></td></tr>
<tr><td colspan="2"></td><td colspan="2"></td></tr>
<tr><td colspan="2"></td><td colspan="2"></td></tr>
<tr><td colspan="2"></td><td colspan="2"></td></tr>
<tr><td colspan="2"></td><td colspan="2"></td></tr>
<tr><td colspan="4">បុគ្គលិកប្រឹក្សាយោបល់ផ្តល់អនុសាសន៍ដើម្បីកែលម្អក្នុងការបំពេញការងាររបស់ក្រុមគោលដៅ:</td></tr>
</table>

ទម្រង់ទី២ ៖ ទម្រង់សង្កេតការពិគ្រោះយោបល់ក្នុងកំឡុងពេលកិច្ចប្រជុំក្រុមប្រឹក្សា ឬ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ (ត្រូវបំពេញដោយអ្នកពិគ្រោះយោបល់)

| | |
|---|---|
| បំពេញដោយ | កាលបរិច្ឆេទ |
| | ទីកន្លែង |
| ក្រុមគោលដៅ | |
| សមាជិកក្រុមប្រឹក្សា<br>☐ ខេត្ត.....................ស្រី..................<br>☐ ក្រុង.....................ស្រី..................<br>☐ ស្រុក....................ស្រី..................<br>សរុប.........................ស្រី.................. | គណៈអភិបាល<br>☐ ខេត្ត.....................ស្រី.....................<br>☐ ក្រុង.....................ស្រី.....................<br>☐ ស្រុក....................ស្រី.....................<br>សរុប.........................ស្រី..................... |
| សមាជិកក្រុមប្រឹក្សាឃុំ ឬ សង្កាត់<br>☐ ឃុំ........................ស្រី..................<br>☐ សង្កាត់.................ស្រី..................<br>សរុប.........................ស្រី.................. | ផ្សេងៗទៀត (សូមបញ្ជាក់)<br>☐ ............................ប្រុស.......ស្រី.......<br>☐ ............................ប្រុស.......ស្រី.......<br>.......................................................<br>សរុប.........................ស្រី...................... |
| ពិពណ៌នាសង្ខេបអំពីកិច្ចប្រជុំក្រុមប្រឹក្សាដែលបានសង្កេត ៖ | |
| ចំណុចខ្លាំងរបស់ក្រុមគោលដៅ | ចំណុចគួរកែលម្អរបស់ក្រុមគោលដៅ |
| | |
| | |
| | |
| អនុសាសន៍ដោយអ្នកពិគ្រោះយោបល់សម្រាប់កែលម្អការអនុវត្តការងាររបស់ក្រុមគោលដៅ | |

ខ. **គន្លឹះសំខាន់ៗសម្រាប់រៀបចំកិច្ចតែងការពិគ្រោះយោបល់** ៖ ដើម្បីសម្របសម្រួលដំណើរការពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធភាព ការរៀបចំកិច្ចតែងការជួយអ្នកពិគ្រោះយោបល់កំណត់ពីវិសាលភាពនៃកិច្ចតែងការសម្រាប់ការពិគ្រោះយោបល់ និងរៀបចំផែនការសកម្មភាពតាមកិច្ចតែងការដែលបានគ្រោង។ អ្នកពិគ្រោះយោបល់គួររៀបចំកិច្ចតែងការមុនពេលធ្វើការពិគ្រោះយោបល់។ កិច្ចតែងការទាំងនេះគួរផ្តោតទៅលើចំណុចសំខាន់ៗដូចខាងក្រោម ៖

- តើសកម្មភាព ឬ ចំណុចសំខាន់អ្វីខ្លះនៃការពិភាក្សាដែលបានឯកភាពគ្នាក្នុងកំឡុងពេលពិគ្រោះយោបល់ចុងក្រោយ?
- តើក្រុមគោលដៅចង់កែលម្អទៅលើផ្នែកណាខ្លះ?
- តើប្រធានបទអ្វីខ្លះដែលអាចមានសម្រាប់ការពិគ្រោះយោបល់បន្ទាប់?
- តើយើងគួរកែលម្អអ្វីខ្លះ ទាក់ទងទៅនឹងដំណើរការ និងវិធីសាស្ត្រសម្រាប់ការពិគ្រោះយោបល់បន្ទាប់?

**គ. គំរូកិច្ចតែងការសម្រាប់ការពិគ្រោះយោបល់**

| ប្រធានបទ | តួនាទីរបស់ប្រធានក្រុមប្រឹក្សាក្នុងដំណើការពិភាក្សា និងការធ្វើសេចក្តី សម្រេចលើបញ្ហានានា | សម្ភារៈ និង ឯកសារយោង |
|---|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀននេះ<br>ប្រធានក្រុមប្រឹក្សានឹងអាចកំណត់បាននូវតួនាទីបន្ថែម ដែលគាត់គួរធ្វើក្នុងដំណើការពិភាក្សានិងការធ្វើសេចក្តីសម្រេចលើបញ្ហានានា | |
| ក្រុមគោលដៅ | ប្រធានក្រុមប្រឹក្សា | |
| រយៈពេល | ៤០នាទី | |
| ដំណើការ (៣០នាទី) | <u>**កំណត់សំគាល់:**</u> មេរៀននេះគួរតែធ្វើឡើងបន្ទាប់ពីមេរៀនទី៣<br>**ការពិភាក្សាពេញអង្គ** (៣០នាទី)<br>អ្នកពិគ្រោះយោបល់ស្នើឱ្យប្រធានក្រុមប្រឹក្សាចែករំលែកគំនិតយោបល់ស្តីពីដំណើរការសម្របសម្រួលការពិភាក្សា និងការធ្វើសេចក្តីសម្រេចលើបញ្ហានានាក្នុងកិច្ចប្រជុំក្រុមប្រឹក្សាលើកមុន និងការសម្តែងតួនៅក្នុងមេរៀនទី៣។<br>(បើសិនជាការសំដែងតួមិនអាចធ្វើបាន នៅក្នុងមេរៀនទី៣សូមរំលងចំណុចនេះ)<br>អ្នកពិគ្រោះយោបល់កត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ។ | |

| | | |
|---|---|---|
| | អ្នកពិគ្រោះយោបល់សួរប្រធានក្រុមប្រឹក្សាៈ តើលោកលោកស្រីមានផ្នែកណាខ្លះដែលមិនទាន់ពេញចិត្តហើយចង់កែលម្អ?<br>អ្នកពិគ្រោះយោបល់កត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ។<br><br>អ្នកពិគ្រោះយោបល់និងប្រធានក្រុមប្រឹក្សាព្រមព្រៀងលើកិច្ចការដែលត្រូវពិគ្រោះយោបល់អំពីការពិភាក្សា និងការដំណើការនៃការធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើចម្លើយដែលបានកត់ត្រាលើក្រដាសផ្ទាំងធំ។<br>អ្នកពិគ្រោះយោបល់នឹងចូលរួមសង្កេតការណ៍នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាលើក ក្រោយ។ | |
| ការសង្ខេប និងសន្និដ្ឋាន (១០នាទី) | អ្នកពិគ្រោះយោបល់សង្ខេបចំនុចរៀនសូត្រសំខាន់ៗស្តីពីដំណើរការសម្របសម្រួលការពិភាក្សា និងការធ្វើសេចក្តីសម្រេចលើបញ្ហានានា និងបញ្ជាក់ពីកម្មវិធីពិគ្រោះយោបល់លើកក្រោយ។ | កម្មវិធីពិគ្រោះយោបល់ |